ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## រូបសញ្ញានិងត្រារបស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណូមពរចាំបាច់នៃការងារ

# សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតរូបសញ្ញានិងត្រារបស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា២ .-**

រូបសញ្ញារបស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានរូបភាពដូចតទៅ៖

- រូបភាពទូទៅនៃរូបសញ្ញាមានរាងរង្វង់មូលផ្នែកខាងក្នុង អមសងខាងដោយខ្សែកោងរាងមូលដាច់ៗដោយអន្លើ បីជាន់ ពណ៌មាស(នៅខាងស្តាំ) និងពណ៌ខៀវ(នៅខាងឆ្វេង)
- ផ្នែកខាងលើនៃខ្សែកោងរាងមូលបីជាន់មានចារឹកអក្សរកាត់ជាភាសាខ្មែរថា "**ក.ជ.វ.ប.ន.**" ដែលបានមកពីពាក្យពេញថា "ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍" និងផ្នែកខាងក្រោមមានចារឹកអក្សរកាត់ជាភាសាអង់គ្លេសថា "N C S T I" ដែលបានមកពីពាក្យពេញថា "National Council of Science, Technology & Innovation"
- ផ្ទៃខាងក្នុងនៃរង្វង់មូលមានរូបសញ្ញាតំណាងចំនួនបីគឺ រង្វង់មូលតូច ក្បាច់កោងរាងគូទខ្យង និងខ្សែសរសៃតូចៗរាងសំណាញ់៖
  - **១-រង្វង់មូលតូច** ជាលេខសូន្យដំបូងគេបង្អស់ដែលត្រូវបានរកឃើញលើសិលាចារឹកខ្មែរ។ រង្វង់មូលតូចនេះតំណាងឱ្យប្រវត្តិសាស្ត្រខ្មែរ បញ្ញាញាណខ្មែរ និងត្រូវបានប្រើប្រាស់ក្នុងគណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកវិទ្យាសម័យទំនើបនិងឌីជីថល។
  - **២-ក្បាច់កោងរាងគូទខ្យង** តំណាងឱ្យលេខមួយខ្មែរនិងវឌ្ឍនបញ្ញាខ្មែរ និងប្រើក្នុងគណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកវិទ្យាសម័យទំនើបនិងឌីជីថល។ ផ្នែកខាងក្នុងនៃរូបសញ្ញានេះ ត្រូវបានរចនាដោយប្រើប្រាស់ទ្រឹស្តីបទសមាមាត្រមាស ដែលមានចំណុចសូន្យទៅត្រង់ផ្ចិតរង្វង់មូលតូច និងមានទិសដៅវង្វិលតាមទ្រនិចនាឡិកា។
  - **៣-ខ្សែសរសៃតូចៗរាងសំណាញ់** រចនាដោយប្រទាក់ក្រឡាគ្នាស្របតាមក្បាច់កោងរាងគូទខ្យង និងជានិមិត្តរូបនៃចក្រវាលពិភពលោក សាមគ្គីភាព កិច្ចសហការ ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធអេកូឡូស៊ី និងនវានុវត្តន៍។
- រូបសញ្ញាមានផ្ទៃនិងអក្សរពណ៌ខៀវ តំណាងឱ្យសេចក្តីស្រលាញ់ ភាពស្មោះត្រង់ ភាពជឿជាក់ និងភាពអង់អាចក្លាហាន។ ផ្ទៃពណ៌មាស តំណាងឱ្យភាពខ្ពង់ខ្ពស់ ភាពថ្លៃថ្នូរ និងភាពបរិសុទ្ធ។ ខ្សែកោងរាងមូលដាច់ដោយអន្លើ បីជាន់ តំណាងឱ្យការរួបរួមគ្នារបស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់កម្ពុជា។

រូបសញ្ញាដែលមានខ្លឹមសារដូចមានចែងខាងលើ ជាឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ។

**មាត្រា៣ .-**

រូបសញ្ញារបស់ **ក.ជ.វ.ប.ន.** ត្រូវបានប្រើដូចខាងក្រោម៖

- ដាក់លើក្បាលលិខិតផ្លូវការរបស់ **ក.ជ.វ.ប.ន.**

- ប្រើក្នុងករណីចាំបាច់ផ្សេងៗដែលកំណត់ដោយ **ក.ជ.វ.ប.ន.**។

**មាត្រា៤ .-**

**ក.ជ.វ.ប.ន.** មានត្រាមូលមួយប្រើសម្រាប់ប្រតិបត្តិការការងារ។ ត្រារបស់ **ក.ជ.វ.ប.ន.** មានវណ្ឌពីរជាន់ រំលេចរូបប្រាសាទអង្គរវត្តកំពូលបីនៅចំកណ្ដាល និងមានអក្សរកាត់ជាភាសាខ្មែរថា "**ក.ជ.វ.ប.ន.**" នៅផ្នែកខាងក្រោមរូបប្រាសាទអង្គរវត្តកំពូលបី។ ផ្នែកខាងលើមានឆ្លាក់អក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" ស្របតាមវណ្ឌ ផ្នែកខាងក្រោមមានឆ្លាក់អក្សរ "**ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**" ស្របតាមវណ្ឌ និងនៅចន្លោះពាក្យទាំងពីរ មានរូបផ្កាចន្ទន៍អមសងខាង។

ត្រាដែលមានខ្លឹមសារដូចមានចែងខាងលើ ជាឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៤រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃអនុក្រឹត្យលេខ..២៤ អនក្រ.បក..ចុះថ្ងៃទី៣១..ខែមករា.....ឆ្នាំ២០២២

គ.ជ.វ.ប.ន.

NCSTI

ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា

ក.ជ.វ.ប.ន.

ក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍